មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ ២០១៩

ឈ្មោះស្ថាប័ន	**មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”)**
គោលដៅគម្រោង	ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឲ្យកម្ពុជាក្លាយទៅជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសមភាពនិងត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ ម.ស.ម.ក គឺជាអង្គការឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការងារផ្តែកទៅលើគុណតម្លៃសមភាព អព្យាក្រឹត្យភាព តម្លាភាព និងការមិនរើសអើង។
រយៈពេល	ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៩

ក្នុងអំឡុងពេលពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៩ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) អនុវត្តសកម្មភាពការងាររបស់ខ្លួន ដូចមានរៀបរាប់ខាងក្រោម ៖

១. ទស្សនភាពនៃសកម្មភាព

ក្នុងអំឡុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក បានចេញឯកសារផ្សព្វផ្សាយចំនួន ៧៤ ពាក់ព័ន្ធនឹងសិទ្ធិមនុស្សក្នុងនោះរួមមាន សេចក្តីថ្លែងការណ៍ លិខិតចំហ សេចក្តីថ្លែងការណ៍រួម សេចក្តីប្រកាសព័ត៌មាន បន្ទាន់អំពីអ្នកការពារសិទ្ធិមនុស្ស កំណត់ត្រាសង្ខេប របាយការណ៍ស្រាវជ្រាវ សលាកបត្រព័ត៌មាន របាយការណ៍រួមផ្តោតលើបញ្ហាជាក់លាក់ ប័ណ្ណព័ត៌មាន និងខិតប័ណ្ណព័ត៌មានមួយចំនួនទៀត។ ឯកសារទាំងនេះចេញផ្សាយក្នុងគោលបំណងតស៊ូមតិ អប់រំ និងលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសិទ្ធិមនុស្សជាច្រើនផ្សេងៗ រួមមានសេរីភាពមូលដ្ឋាន សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងសិទ្ធិជនជាតិដើមភាគតិចជាដើម។

ម.ស.ម.ក បន្តឃ្លាំមើលតាមរយៈសារព័ត៌មានក្នុងគោលបំណងទទួលបានព័ត៌មានទាន់ហេតុការណ៍ជុំវិញព្រឹត្តិការណ៍នានានិងបញ្ហាសំខាន់ៗមួយចំនួនដែលផ្តោតទៅលើសិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្សជាទូទៅ សិទ្ធិស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ («អ្នកស្រឡាញ់ភេទដូចគ្នា») និងស្ថានភាពនៃសេរីភាពមូលដ្ឋាននៅទូទាំងប្រទេស។ ជាសរុបក្នុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក

បានប្រមូលព័ត៌មានសរុបចំនួន ២២៥២ អត្ថបទដែលចេញផ្សាយពាក់ព័ន្ធនឹងសិទ្ធិសេរីភាពមូលដ្ឋាន សេរីភាពខាងការជួបប្រជុំ សេរីភាពខាងការបញ្ចេញមតិ សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និងសិទ្ធិស្ត្រីជាដើម។

នៅក្នុងឱកាសនៃទិវាសិទ្ធិសិទ្ធិមនុស្សអន្តរជាតិថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ ម.ស.ម.ក បានចេញផ្សាយរបាយការណ៍ស្រាវជ្រាវមួយស្តីពីសិទ្ធិមិនត្រូវបានរើសអើងដោយផ្អែកលើមូលដ្ឋាននិន្នាការភេទអត្តសញ្ញាណយេនឌ័រនិងការបង្ហាញនូវទំនោរយេនឌ័រនិងលក្ខណៈភេទក្នុងវិស័យការងារនៅប្រទេសកម្ពុជា និងការតាំងពិព័រណ៌កម្រងជីវប្រវត្តិរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រីនិងសកម្មជនអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា ក្នុងគោលបំណងផ្សព្វផ្សាយអំពីរបកគំហើញនៃការស្រាវជ្រាវនិងផ្សព្វផ្សាយសិទ្ធិនិងសំឡេងរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី។ ម្យ៉ាងទៀតគម្រោងសង្កេតការណ៍សវនាការបានចេញផ្សាយព្រឹត្តិបត្រព័ត៌មានចំនួនពីរ(មួយពាក់ព័ន្ធនឹងសិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ និងមួយទៀតស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់អនីតិជន ព្រមទាំង របាយការណ៍ប្រចាំឆ្នាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍ ដែលធ្វើឡើងចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ។ ជាពិសេស ម.ស.ម.ក ក៏បានចេញបណ្ណព័ត៌មានជាច្រើនទៀតពាក់ព័ន្ធធុរៈកិច្ចនិងសិទ្ធិមនុស្ស គោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ការពិនិត្យជាសកលតាមពេលវេលាកំណត់ សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា និងសិទ្ធិសេរីភាពមូលដ្ឋាន។

ក្នុងអំឡុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក បានរៀបចំការផ្សាយផ្ទាល់កម្មវិធីពិភាក្សាតាមវិទ្យុចំនួន ១៤៨ លើកដោយផ្តោតលើប្រធានបទនានាតាមវិស័យនីមួយៗដូចមានដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ការពិភាក្សាអំពីច្បាប់និងការវិភាគប្រចាំសប្តាហ៍។ ក្នុងកម្មវិធីពិភាក្សាទាំងនោះសុទ្ធតែមានការអញ្ជើញភាគីពាក់ព័ន្ធសំខាន់ៗពីសង្គមស៊ីវិល មេធាវីនិងរដ្ឋាភិបាលដើម្បីចូលរួមចែករំលែកនូវគំនិតយោបល់របស់ពួកគេ។ ពាល់កម្មវិធីពិភាក្សាទាំងអស់ក៏មានផ្សព្វផ្សាយបន្តផ្ទាល់នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក ផងដែរ ដែលទទួលបានការចុច Like ចំនួន ៨២០២ ចែករំលែកបន្តចំនួន៤៥២៨ និងចូលទស្សនាចំនួន ៣៥៣២២ ។

ម.ស.ម.ក បានរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល វគ្គបណ្តុះបណ្តាលតាមដានបន្ត ទាក់ទងនឹងការតស៊ូមតិ ច្បាប់ ធុរកិច្ចនិងសិទ្ធិមនុស្ស និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ចំនួន១២ លើក ដោយមានអ្នកចូលរួមសរុបចំនួន ៣៨៣ នាក់ (ស្ត្រីមានចំនួន១៥៩ ប្រុសចំនួន១៣៦ នាក់និងអ្នកស្រលាញ់ភេទដូចគ្នាចំនួន៤៨ នាក់)។ លើសពីនេះក៏មានកិច្ចប្រជុំចំនួន១២ លើកផ្សេងទៀតផងដែរ រួមមាន ការប្រជុំបណ្តាញកិច្ចពិភាក្សាជាមួយក្រុមគោលដៅ និងកម្មវិធីផ្សព្វផ្សាយមួយចំនួនផងដែរដោយមានអ្នកចូលរួមចំនួន ២៨៨(ស្ត្រីមានចំនួន៨១ ប្រុសចំនួន១៥៦ នាក់និងអ្នកស្រលាញ់ភេទដូចគ្នាចំនួន៥១ នាក់)។ ឧទាហរណ៍មួយក្នុងចំណោមវគ្គបណ្តុះបណ្តាលនោះគឺកម្មវិធីវគ្គបំពាក់បំប៉នអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែល ម.ស.ម.ក បានរៀបចំឡើងរយៈពេលបីថ្ងៃចំនួន ៣ វគ្គ ដោយមានការចូលរួមពីនិស្សិតច្បាប់។ នៅថ្ងៃចុងក្រោយនៃ

កម្មវិធីនេះ ម.ស.ម.ក បានសម្របសម្រួលអោយនិស្សិតទាំងនោះបានចូលរួមសង្កេតការណ៍សវនាការដើម្បីឈ្វេងយល់បន្ថែមអំពីនីតិវិធីនៃការជំនុំជម្រះ។ វគ្គបណ្តុះបណ្តាលនោះមានការចូលរួមពីនិស្សិតចំនួន ៨២ នាក់ ក្នុងនោះមានស្ត្រីចំនួន ៣៥នាក់ ព្រះសង្ឃចំនួន៤ អង្គ និងស្ត្រីមានពិការភាពមួយនាក់ ។

ឧទាហរណ៍មួយផ្សេងទៀតគឺសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី២ជាមួយនឹងរដ្ឋាភិបាលនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩។ ម.ស.ម.ក បានសហការរៀបចំជាមួយអង្គការដៃគូនូវកិច្ចពិភាក្សាអំពីគោលនយោបាយសាធារណៈដើម្បីលើកកម្ពស់សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ អង្គការសង្គមស៊ីវិលដែលធ្វើការងារផ្នែកលើកកម្ពស់និន្នាការភេទនិងអត្តសញ្ញាណយេនឌ័របានចូលរួមក្នុងកម្មវិធីនេះព្រមទាំងតំណាងមកពីគណៈកម្មការសិទ្ធិមនុស្សកម្ពុជា ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ កម្មវិធីនេះមានគោលបំណងបញ្ជ្រាបបញ្ហារបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាទៅដល់អ្នកតាក់តែងច្បាប់និងមន្ត្រីរដ្ឋាភិបាល និងបង្កើតឲ្យមានបរិយាកាសយោគយល់គ្នា និងកិច្ចសន្ទនារវាងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានិងអ្នកតាក់តែងច្បាប់និងមន្ត្រីរដ្ឋាភិបាល ព្រមទាំងបង្កើតវិធានការតាមដាន និងបង្កើតឲ្យមានបរិយាកាសកិច្ចសហប្រតិបត្តិការផ្នែកគោលនយោបាយសម្រាប់សង្គមស៊ីវិលផងដែរ។ កិច្ចសន្ទនានេះដើរតួយ៉ាងសំខាន់ដើម្បីឲ្យមានការផ្លាស់ប្តូរគោលនយោបាយដោយបញ្ចូលកិច្ចការពារជាពិសេសដល់អ្នកស្រលាញ់ភេទដូចគ្នានៅក្នុងច្បាប់នាពេលអនាគត។

ជាផ្នែកនៃគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ក្នុងឆ្នាំ២០១៩ ម.ស.ម.ក បានសង្កេតការណ៍សវនាការក្នុងករណីព្រហ្មទណ្ឌចំនួន២១៥ នៅសាលាឧទ្ធរណ៍។

ម.ស.ម.ក ក៏បានផលិតវីដេអូអប់រំចំនួន ៧ រួមមាន៖

1. វីដេអូអប់រំស្តីពី សេរីភាពសារព័ត៌មាន ដែលបង្ហាញពីអ្វីជាសេរីភាពសារព័ត៌មាន ព្រមទាំងសិទ្ធិដែលបានចែងក្នុងក្របខណ្ឌច្បាប់ពាក់ព័ន្ធសិទ្ធិសេរីភាពសារព័ត៌មាន។
2. វីដេអូអប់រំស្តីពី សារៈសំខាន់នៃសេរីភាពសារព័ត៌មាន បង្ហាញអំពីទស្សនៈផ្សេងៗរបស់សាធារណៈជនដែលមានធ្វើការនៅក្នុងវិស័យផ្សេងៗ ជុំវិញសារៈសំខាន់នៃសេរីភាពសារព័ត៌មានក្នុងឱកាសទិវាសេរីភាពសារព័ត៌មានពិភពលោក ។
3. វីដេអូអប់រំស្តីពី សំឡេងខ្ញុំ សិទ្ធិខ្ញុំ ដែលបានបង្ហាញអំពីទស្សនៈផ្សេងៗរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងអ្នកស្រលាញ់ភេទដូចគ្នា ពាក់ព័ន្ធនឹងយេនឌ័រ។
4. វីដេអូអប់រំ៤ ផ្សេងទៀត អ្នកបន្តវេន អ្នកតាព្រៃ ពាក្យពិត និង ដើម្បីអ្នក បង្ហាញអំពីរឿងប្រវត្តិជនរងគ្រោះនៃអំពើនិទណ្ឌភាព។

វីដេអូទាំងនេះសុទ្ធតែបានផ្សព្វផ្សាយតាមរយៈគេហទំព័ យូធូប និង រហ្វេសបុករបស់ម.ស.ម.ក និងទទួលបានការចាប់អារម្មណ៍ជាខ្លាំង។

២. កំណត់សម្គាល់និងការប្រឈម

នៅឆ្នាំ២០១៩ ម.ស.ម.ក បានភ្ជាប់ទំនាក់ទំនងជាមួយអាជ្ញាធរនិងវិស័យឯកជនតាមរយៈការផ្តល់វគ្គសិក្ខាសាលាស្តីពី «កាតព្វកិច្ចរបស់រដ្ឋ និងដំណើរការត្រួតពិនិត្យដ៏ត្រឹមត្រូវទៅលើសិទ្ធិមនុស្ស» និងសិក្ខាសាលាវាយតម្លៃបញ្ចប់។ យ៉ាងតិចណាស់មានអ្នកចូលរួមចំនួន១០ នាក់ ដែលជាអាជ្ញាធរមកពីថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិបានចូលរួមសិក្ខាសាលាចំនួន២ របស់ ម.ស.ម.ក។

អង្គការមិនមែនរដ្ឋាភិបាលនៅតែត្រូវបានតម្រូវអោយបំពេញនូវលក្ខខណ្ឌរដ្ឋបាលមួយចំនួន ក្នុងនោះរួមទាំងការតម្រូវអោយរាយការណ៍ទៅអាជ្ញាធរ ឬអាជ្ញាធរចុះមកតាមដានកត់ត្រាព័ត៌មានពាក់ព័ន្ធនឹងព្រឹត្តិការណ៍សកម្មភាពដែលរៀបចំឡើងនៅតាមមូលដ្ឋាន ដូចជាកត់ត្រាប្រធានបទ របៀបវារៈ ចំនួនអ្នកចូលរួមនិងថតរូបអំពីព្រឹត្តិការណ៍ ឬអ្នកចូលរួមជាដើមដើម្បីរាយការណ៍ទៅថ្នាក់លើ ។

៣. មេរៀន

ថ្វីបើមានការប្រឈមការពិតត្បិតយ៉ាងណាក្តី ម.ស.ម.ក យល់ឃើញថាការបន្តសកម្មភាពតស៊ូមតិប្រកបដោយគោលការណ៍ ដោយតុល្យភាព និងការចូលរួមក្នុងកិច្ចពិភាក្សាជាមួយដៃគូពាក់ព័ន្ធជាកិច្ចការចាំបាច់ដើម្បីបន្តកិច្ចគាំពារនិងលើកកម្ពស់សិទ្ធិមនុស្ស។ ម.ស.ម.ក នៅតែប្រកាន់គោលជំហរប្រកបដោយគោលការណ៍ទៅលើបញ្ហាសិទ្ធិមនុស្ស ទស្សនៈមិនលម្អៀង និងតុល្យភាព។

៤. យេនឌ័រ និងគោលការណ៍ផ្អែកលើសិទ្ធិជាមូលដ្ឋាន

ក្នុងឆ្នាំ២០១៩ ម.ស.ម.ក នៅតែអនុវត្តសកម្មភាពការងាររបស់ខ្លួនដើម្បីជានាយ៉ាងណាដើម្បីឲ្យមានសមភាពយេនឌ័រ ជាពិសេសសការចូលរួមរបស់ស្ត្រី។ នៅគ្រប់ពេលទាំងអស់ ម.ស.ម.ក តែងតែលើកឡើងពីស្ថានភាពផ្លូវច្បាប់ស្មើភាពគ្នារវាងបុរស ស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាទាក់ទងនឹងសិទ្ធិមនុស្ស។

លើសពីនោះ ម.ស.ម.ក បានរៀបចំព្រឹត្តិការណ៍សំខាន់មួយចំនួនដើម្បីលើកកម្ពស់ស្ត្រី និងសមភាពយេនឌ័រនៅក្នុងឱកាសនៃទិវានារីអន្តរជាតិ ០៨ មីនា ឆ្នាំ២០១៩ និងនៅតែបន្តផ្តល់ជំនួយផ្នែកច្បាប់ មនុស្សធម៌ និងផ្លូវចិត្តតាមលទ្ធភាពដែលអាចធ្វើទៅបានដល់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាដែលបានប្រឈមនឹងអំពើហិង្សា ការយាយី និងការគំរាមកំហែងដោយសារការងាររបស់ពួកគេ។

៥. ឧបសម្ពន្ធ ៖ ឯកសារចេញផ្សាយសំខាន់ៗរបស់ ម.ស.ម.ក រួមមាន ៖

- របាយការណ៍ប្រចាំឆ្នាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍
- សៀវភៅរឿងប្រវត្តិជនរងគ្រោះនៃអំពើនិទណ្ឌភាព
- ខិត្តប័ណ្ណព័ត៌មានអំពីការពិនិត្យជាសកលតាមកាលកំណត់សម្រាប់ប្រទេសកម្ពុជា៖ដំណាក់កាលនៃអនុវត្ត
- ខិតប័ណ្ណព័ត៌មានអំពីសិទ្ធិរបស់ស្ត្រី៖ ច្បាប់ជាតិនិងច្បាប់អន្តរជាតិ

--- ចប់ ---